*ឧបសម្ព័ន្ធទី២-ក២ នៃប្រកាសលេខ២៨៩ ក.ប/ប្រ.ក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦*
*សម្រាប់សហជីពថ្នាក់សហព័ន្ធឡើង*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# លក្ខន្តិកៈ
# នៃ
# សហព័ន្ធសហជីព/សហភាពសហជីព

**ឈ្មោះ.....................................**

**ឆ្នាំ..............**

# មាតិកា

ទំព័រ

សេចក្តីថ្លែងការណ៍ស្តីពីគោលបំណង ..........

ជំពូកទី១ ឈ្មោះ អាសយដ្ឋាន គំរូសញ្ញា និងគំរូត្រា

ប្រការ១ ..........

ប្រការ២ ..........

ប្រការ៣ ..........

ប្រការ៤ ..........

ជំពូកទី២ គោលដៅ និងដែនអនុវត្ត

ប្រការ៥ ..........

ប្រការ៦ ..........

ជំពូកទី៣ រចនាសម្ព័ន្ធ និងតួនាទីភារកិច្ច

ប្រការ៧ ..........

ប្រការ៨ ..........

ជំពូកទី៤ សមាជិកភាព

ប្រការ៩ ..........

ប្រការ១០ ..........

ប្រការ១១ ..........

ប្រការ១២ ..........

ជំពូកទី៥ សិទ្ធិ និងករណីយកិច្ចរបស់សមាជិក

ប្រការ១៣ ..........

ប្រការ១៤ ..........

ជំពូកទី៦ ហិរញ្ញវត្ថុរបស់សហជីព

ប្រការ១៥ ..........

ប្រការ១៦ ..........

ប្រការ១៧ ..........

ប្រការ១៨ ..........

ប្រការ១៩ ..........

ជំពូកទី៧ ការថែរក្សាកំណត់ត្រាហិរញ្ញវត្ថុ របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាពប្រចាំឆ្នាំ

ប្រការ២០ ..........

ប្រការ២១ ..........

ជំពូកទី៨ សន្និបាត

ប្រការ២២ ..........

ជំពូកទី៩ ការរៀបចំបទបញ្ជាផ្ទៃក្នុងរដ្ឋបាល ការកែប្រែលក្ខន្តិកៈ និងការរំលាយ

ប្រការ២៣ ..........

ប្រការ២៤ ..........

ប្រការ២៥.................................................................................................
ជំពូកទី១០ កូដកម្ម
ប្រការ២៦.................................................................................................
ប្រការ២៧.................................................................................................
ជំពូកទី១១ អ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាល
ប្រការ២៨.................................................................................................
ប្រការ២៩.................................................................................................
ជំពូកទី១២ អន្តរប្បញ្ញត្តិ
ប្រការ៣០.................................................................................................
ជំពូកទី១៣ អវសានប្បញ្ញត្តិ
ប្រការ៣១.................................................................................................

# សេចក្តីថ្លែងការណ៍ស្តីពីគោលបំណង

សហព័ន្ធសហជីព/សហភាពសហជីពឈ្មោះ..................... ត្រូវបានបង្កើតឡើងដោយការរួបរួមគ្នារវាងសហជីពមូលដ្ឋានចំនួន........... *(យ៉ាងតិចចំនួន៧សហជីពមូលដ្ឋានដែលមានបញ្ជិកា សម្រាប់សហព័ន្ធសហជីព)* ឬ *សហព័ន្ធសហជីពចំនួន.........* *(យ៉ាងតិចចំនួន៥សហព័ន្ធសហជីពដែលមានបញ្ជិកា សម្រាប់សហភាពសហជីព)* ដែលមាន......... *(វិជ្ជាជីវៈដូចគ្នា ឬប្រហាក់ប្រហែលគ្នាដែលមានសកម្មភាពសេដ្ឋកិច្ចដូចគ្នា ឬប្រហាក់ប្រហែលគ្នា ...)* ក្នុងគោលបំណង ......... ។ សហជីពមិនចូលរួមធ្វើសកម្មភាពនយោបាយ និងមិនបម្រើនិន្នាការនយោបាយណាមួយឡើយ។

...................................

ធ្វើនៅ....... ថ្ងៃទី....... ខែ....... ឆ្នាំ២០១៦

| ឈ្មោះសហជីពមូលដ្ឋាន/សហព័ន្ធសហជីព | ឈ្មោះប្រធាន | ហត្ថលេខា |
|---|---|---|
| ១. | | |
| ២. | | |
| ៣. | | |
| ៤. | | |
| ៥. | | |
| ៦. | | |
| ៧. | | |

## ជំពូកទី១
## ឈ្មោះ អាសយដ្ឋាន តំរូសញ្ញា និងតំរូត្រា

**ប្រការ១ ._** *(ឈ្មោះ និងឈ្មោះជាអក្សរកាត់)*

សហព័ន្ធសហជីព/សហភាពសហជីពមានឈ្មោះជាភាសាខ្មែរ.................. ដែលហៅកាត់ថា.................. និងមានឈ្មោះជាភាសាអង់គ្លេស.................. ដែលហៅកាត់ថា...........។

**ប្រការ២ ._** *(អាសយដ្ឋាន)*

សហព័ន្ធសហជីព/សហភាពសហជីព ............................................................................ មានអាសយដ្ឋាននៅផ្ទះលេខ....... ផ្លូវ............ ភូមិ............ ឃុំ/សង្កាត់.............. ស្រុក/ខណ្ឌ/ក្រុង.............. រាជធានី/ខេត្ត..............................។

**ប្រការ៣ ._** *(តំរូសញ្ញា)*

សហព័ន្ធសហជីព/សហភាពសហជីព.............................. មានតំរូសញ្ញាដូចតទៅ៖

*(សូមភ្ជាប់រូបសញ្ញានៅទីនេះ)*

- រូបសញ្ញានេះមាន *(បរិយាយទម្រង់ និងរូបដែលប្រើក្នុងរូបសញ្ញា)*
    - ..........................................................
    - ..........................................................
    - ..........................................................
- អត្ថន័យនៃរូបសញ្ញា
    - រូប................. តំណាងឱ្យ............................
    - ពណ៌............ តំណាងឱ្យ..........................
    - ..........................................................

**ប្រការ៤ ._** *(តំរូត្រា)*

សហព័ន្ធសហជីព/សហភាពសហជីពមានត្រាដូចខាងក្រោម៖

*(សូមប្រថាប់តំរូត្រានៅទីនេះ)*

## ជំពូកទី២
## គោលដៅ និងដែនអនុវត្ត

**ប្រការ៥ ._** *(គោលដៅ)*

សហព័ន្ធសហជីព/សហភាពសហជីព ត្រូវបានបង្កើតឡើងដោយការរួបរួមគ្នានៃសហជីពមូលដ្ឋានចំនួន......... *(យ៉ាងតិចចំនួន៧សហជីពមូលដ្ឋានដែលមានបញ្ជិកា សម្រាប់សហព័ន្ធសហជីព)* ឬ សហព័ន្ធសហជីពចំនួន......... *(យ៉ាងតិចចំនួន៥សហព័ន្ធសហជីពដែលមានបញ្ជិកា សម្រាប់សហភាពសហជីព)* ដែលមាន......... *(វិជ្ជាជីវៈដូចគ្នា ឬ ប្រហាក់ប្រហែលគ្នាដែលមានសកម្មភាពសេដ្ឋកិច្ចដូចគ្នា ឬប្រហាក់ប្រហែលគ្នា...)* មានគោលបំណង និងគោលដៅដូចខាងក្រោម៖

- ការពារ និងគោរពសិទ្ធិសេរីភាពនិងផលប្រយោជន៍របស់កម្មករ និយោជិតនៃ.............. *(វិជ្ជាជីវៈដូចគ្នា ឬ ប្រហាក់ប្រហែលគ្នាដែលមានសកម្មភាពសេដ្ឋកិច្ចដូចគ្នា ឬប្រហាក់ប្រហែលគ្នា)* ដែលជាសមាជិក
- ផ្តល់ប្រឹក្សាយោបល់ដល់សហជីពមូលដ្ឋានដែលជាសមាជិកក្នុងការដោះស្រាយវិវាទ ការចរចាជាសមូហភាពជាមួយនិយោជក
- ចូលរួមចំណែកធ្វើឱ្យមានសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈនៃ......... *(វិជ្ជាជីវៈដូចគ្នា ឬប្រហាក់ប្រហែលគ្នាដែលមានសកម្មភាពសេដ្ឋកិច្ចដូចគ្នា ឬប្រហាក់ប្រហែលគ្នា)*
- ចូលរួមចំណែកក្នុងការអភិវឌ្ឍលក្ខខណ្ឌការងារសមរម្យ បង្កើនផលិតភាព និងជំនាញដល់កម្មករ និយោជិតដែលជាសមាជិកនៃសហជីពមូលដ្ឋាន សំដៅទាក់ទាញការវិនិយោគ និងបង្កើតការងារថ្មីជូនប្រជាពលរដ្ឋ
- មិនចូលរួមធ្វើសកម្មភាពនយោបាយ ឬបម្រើនិន្នាការនយោបាយណាមួយ

- ........................................................................................................ ។

**ប្រការ៦ ៈ** *(ដែនអនុវត្ត)*

សហព័ន្ធសហជីព/សហភាពសហជីព............ មានដែនអនុវត្តនៅក្នុង.............*(វិជ្ជាជីវៈដូចគ្នា ឬប្រហាក់ប្រហែលគ្នាដែលមានសកម្មភាពសេដ្ឋកិច្ចដូចគ្នា ឬប្រហាក់ប្រហែលគ្នា...)*

## ជំពូកទី៣
## រចនាសម្ព័ន្ធ និងតួនាទីភារកិច្ច

**ប្រការ៧ ៈ** *(រចនាសម្ព័ន្ធ)*

សហព័ន្ធសហជីព/សហភាពសហជីព...................... មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- ប្រធាន
- អនុប្រធាន
- អគ្គលេខាធិការ
- អគ្គហេរញ្ញិក
- ........................

**ប្រការ៨ ៈ** *(តួនាទី និងភារកិច្ច)*

ប្រធានសហព័ន្ធសហជីព/សហភាពសហជីពមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ................................................។

អនុប្រធានសហព័ន្ធសហជីព/សហភាពសហជីពមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ................................................។

អគ្គលេខាធិការសហព័ន្ធសហជីព/សហភាពសហជីពមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ................................................។

អគ្គហេរញ្ញិកសហព័ន្ធសហជីព/សហភាពសហជីពមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ................................................។

..........................................................................។

## ជំពូកទី៤
## សមាជិកភាព

**ប្រការ៩ ៈ** *(លក្ខខណ្ឌនៃការចូលជាសមាជិក)*

ដើម្បីចូលជាសមាជិកនៃសហព័ន្ធសហជីព/សហភាពសហជីព.................... សហជីពមូលដ្ឋាន/សហព័ន្ធសហជីពត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានដែនអនុវត្តដូចមានចែងក្នុងប្រការ៦ខាងលើ
- ដាក់លិខិតសុំចូលជាសមាជិកដែលបានចុះហត្ថលេខា ឬផ្តិតស្រាមដៃដោយថ្នាក់ដឹកនាំគ្រប់គ្រងសហជីពមូលដ្ឋាន/សហព័ន្ធសហជីព ទៅសហព័ន្ធសហជីព/សហភាពសហជីព ក្រោយពីទទួលបានការសម្រេចយល់ព្រមឱ្យចូលពីកម្មករ និយោជិតដែលជាសមាជិករបស់សហជីពមូលដ្ឋាន តាមរយៈការបោះឆ្នោតយល់ព្រមដោយសំឡេងភាគច្រើនដាច់ខាត ស្របតាមលក្ខន្តិកៈរបស់សហជីពមូលដ្ឋាន/សហព័ន្ធសហជីពនីមួយៗ
- បានរៀបរាប់អំពីកាតព្វកិច្ចនៃកម្មករ និយោជិតដែលជាសមាជិកសហជីពមូលដ្ឋានរបស់ខ្លួនមានចំពោះសហព័ន្ធសហជីព/សហភាពសហជីព ជាអាទិ៍ កាតព្វកិច្ចបង់ប្រាក់ភាគទានប្រចាំខែបន្ថែមដែលត្រូវបង់ដោយផ្ទាល់តាមរយៈនិយោជក ទៅគណនីធនាគាររបស់សហព័ន្ធសហជីព/សហភាពសហជីព អាណត្តិរបស់ថ្នាក់ដឹកនាំសហព័ន្ធសហជីព ឬសហភាពសហជីព....
- ..........................................................

សហព័ន្ធសហជីព/សហភាពសហជីពនឹងផ្តល់បណ្ណសមាជិកជូនកម្មករ និយោជិតដែលជាសមាជិកសហជីពមូលដ្ឋានដែលបានចូលជាសមាជិក។

**ប្រការ១០ ._** *(ការដកខ្លួនចេញពីសហព័ន្ធសហជីព/សហភាពសហជីព)*

សហជីពមូលដ្ឋាននីមួយៗ/សហព័ន្ធសហជីពនីមួយៗ មានសិទ្ធិចាកចេញពីសហព័ន្ធសហជីព/សហភាពសហជីព តាមរយៈលិខិតដែលបានចុះហត្ថលេខា ឬផ្តិតស្រាមដៃដោយថ្នាក់ដឹកនាំគ្រប់គ្រងសហជីពមូលដ្ឋាន/សហព័ន្ធសហជីព ជាក់ជូនទៅសហព័ន្ធសហជីព/សហភាពសហជីព ក្រោយពីមានការសម្រេចពីកម្មករ និយោជិតដែលជាសមាជិករបស់សហជីពមូលដ្ឋាន តាមរយៈការបោះឆ្នោតយល់ព្រមឱ្យចាកចេញពីសហព័ន្ធសហជីព/សហភាពសហជីព ដោយសំឡេងភាគច្រើនដាច់ខាត ស្របតាមលក្ខន្តិកៈរបស់សហជីពមូលដ្ឋាននីមួយៗ។

គ្មានបុគ្គលណាអាចរារាំងដល់សិទ្ធិរបស់កម្មករ និយោជិត ដែលជាសមាជិករបស់សហជីពមូលដ្ឋាន ឬសហព័ន្ធសហជីព ក្នុងការសម្រេចចិត្តដកខ្លួនចេញពីសហព័ន្ធសហជីព/សហភាពសហជីពបានឡើយ។

**ប្រការ១១ ._** *(ការបាត់បង់សមាជិកភាព)*

សមាជិកភាពនៃសហជីពមូលដ្ឋាន/សហព័ន្ធសហជីព ត្រូវបានបាត់បង់ក្នុងករណីដូចខាងក្រោម៖

- ការសុំចេញពីសហព័ន្ធសហជីព/សហភាពសហជីព ដោយសហជីពមូលដ្ឋាន/សហព័ន្ធសហជីព តាមឆន្ទៈរបស់កម្មករ និយោជិត ដែលជាសមាជិកសហជីពមូលដ្ឋាននៃសហព័ន្ធសហជីព/សហភាពសហជីពនោះ
- ដែនអនុវត្តរបស់សហជីពមូលដ្ឋានត្រូវបានកែប្រែខុសពីដែនអនុវត្តរបស់សហព័ន្ធសហជីព *(សម្រាប់កម្រិតសហព័ន្ធសហជីព)*
- សហជីពមូលដ្ឋានត្រូវបានរំលាយ ឬលាយ *(សម្រាប់កម្រិតសហព័ន្ធសហជីព)*
- សហព័ន្ធសហជីពត្រូវបានរំលាយ *(សម្រាប់កម្រិតសហភាពសហជីព)*
- ការខកខានក្នុងការបង់ប្រាក់ភាគទានចំនួន.......ខែ
- ......................................................................

**ប្រការ១២ ._** *(វិន័យ និងទណ្ឌកម្ម)*

......................................................................................

## ជំពូកទី៥
## សិទ្ធិ និងករណីយកិច្ចរបស់សមាជិក

**ប្រការ១៣ ._** *(សិទ្ធិរបស់សមាជិក)*

សមាជិកមានសិទ្ធិជាអាទិ៍៖

- ឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំគ្រប់គ្រងសហជីព
- បោះឆ្នោតជាសម្ងាត់ក្នុងការសម្រេចធ្វើកូដកម្ម កែប្រែលក្ខន្តិកៈ និងជ្រើសរើសអ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សហព័ន្ធសហជីព/សហភាពសហជីព
- .......................................................
- .......................................................
- អនុវត្តនូវសិទ្ធិដទៃផ្សេងទៀតដែលចាំបាច់សម្រាប់ការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួន។

សមាជិកសហព័ន្ធសហជីព/សហភាពសហជីព អនុវត្តសិទ្ធិទៅតាមឆន្ទៈកម្មករ និយោជិតដែលជាសមាជិកសហជីពមូលដ្ឋានរបស់ខ្លួន។

**ប្រការ១៤ ._** *(ករណីយកិច្ចរបស់សមាជិក)*

សមាជិកសហព័ន្ធសហជីព/សហភាពសហជីព មានករណីយកិច្ចជាអាទិ៍៖

- គោរពច្បាប់ និងបទប្បញ្ញត្តិទាំងឡាយដែលមានជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា
- គោរពលក្ខន្តិកៈរបស់សហព័ន្ធសហជីព/សហភាពសហជីព
- បង់ប្រាក់ភាគទាន
- ........................................................។

## ជំពូកទី៦
## ហិរញ្ញវត្ថុរបស់សហជីព

**ប្រការ១៥ ._** *(ប្រភពធនធាន និងហិរញ្ញវត្ថុ)*

ប្រភពធនធាន និងហិរញ្ញវត្ថុរបស់សហព័ន្ធសហជីព/សហភាពសហជីព បានមកពី៖

- ភាគទានប្រចាំខែពីសមាជិកសហព័ន្ធសហជីព/សហភាពសហជីព យ៉ាងតិចចំនួន....... រៀល ក្នុងមួយខែ
- ចំណូលដែលបានមកពីសកម្មភាពរកប្រាក់ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហជីព
- អំណោយ និងជំនួយធនធានហិរញ្ញវត្ថុដែលទទួលបានដោយស្របច្បាប់។

សហព័ន្ធសហជីព/សហភាពសហជីព មានគណនីធនាគារលេខ........................................................ នៅធនាគារ..........................................................។ រាល់ថវិការបស់សហព័ន្ធសហជីព/សហភាពសហជីព ជារូបិយបណ្ណ ឬមូលទានបត្រ នឹងរក្សាទុកនៅក្នុងគណនីធនាគារនេះ។

**ប្រការ១៦ ._** *(របៀបបទនៃការកំណត់ចំនួនប្រាក់ភាគទាន និងការបង់ប្រាក់ភាគទានប្រចាំខែ)*

ចំនួនប្រាក់ភាគទានសមាជិកភាពដែលកម្មករ និយោជិតរបស់សហជីពមូលដ្ឋាន និងប្រាក់ភាគទានរបស់សហជីពមូលដ្ឋាន/សហព័ន្ធសហជីព ត្រូវបង់ជូនទៅសហព័ន្ធសហជីព/សហភាពសហជីព ត្រូវកំណត់ដោយមហាសន្និបាត ឬសន្និបាតរបស់សហព័ន្ធសហជីព/សហភាពសហជីព។

សមាជិកសហជីពត្រូវធ្វើលិខិតយល់ព្រមជាលាយលក្ខណ៍អក្សរទៅនិយោជករបស់ខ្លួន ឱ្យកាត់ប្រាក់ភាគទានសមាជិកភាពបន្ថែមយ៉ាងតិចចំនួន.......រៀលក្នុងមួយខែ ពីប្រាក់ឈ្នួលប្រចាំខែរបស់ខ្លួន ជាស្វ័យប្រវត្តិទៅគណនីធនាគាររបស់សហព័ន្ធសហជីព/សហភាពសហជីព ដែលសហជីពមូលដ្ឋានរបស់ខ្លួនជាសមាជិក លេខ.................... ........................... នៅធនាគារ..........................................................។

សហជីពមូលដ្ឋាន/សហព័ន្ធសហជីព ដែលជាសមាជិករបស់សហព័ន្ធសហជីព/សហភាពសហជីព ត្រូវធ្វើលិខិតយល់ព្រមជាលាយលក្ខណ៍អក្សរទៅធនាគារដែលខ្លួនមានគណនី ឱ្យកាត់ប្រាក់ភាគទានសមាជិកភាពរបស់ខ្លួនចំនួន .........រៀល ជាស្វ័យប្រវត្តិទៅគណនីធនាគាររបស់សហព័ន្ធសហជីព/សហភាពសហជីពលេខ............................ នៅធនាគារ................................។

.........................................................................................................................។

**ប្រការ១៧ ._** *(វិយោគកម្មនៃហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិ)*

សហព័ន្ធសហជីព/សហភាពសហជីពមានគណនីធនាគារ និងទ្រព្យសម្បត្តិដាច់ដោយឡែក ផ្សេងពីអ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាល។

**ប្រការ១៨ ._** *(ការប្រើប្រាស់ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ)*

ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិដែលសហព័ន្ធសហជីព/សហភាពសហជីពមាន គឺប្រើប្រាស់សម្រាប់តែបម្រើឱ្យផលប្រយោជន៍របស់សហព័ន្ធសហជីព/សហភាពសហជីពតែប៉ុណ្ណោះ។

ការប្រើប្រាស់ហិរញ្ញវត្ថុមានដូចខាងក្រោម៖

- ចំណាយប្រចាំថ្ងៃ ដូចជាសម្ភារការិយាល័យ ទឹក ភ្លើង និងការទំនាក់ទំនង
- ចំណាយលើការជួលទីស្នាក់ការ មធ្យោបាយ ប្រតិបត្តិការ
- ចំណាយលើការអប់រំបណ្តុះបណ្តាលស្តីពីចំណេះដឹងផ្នែកច្បាប់ និងវិជ្ជាជីវៈ
- ចំណាយលើសេវាប្រឹក្សាផ្នែកច្បាប់ និងការអនុវត្តជាក់ស្តែងដល់សមាជិករបស់ខ្លួន
- ចំណាយលើការរៀបចំបង្កើតសហករណ៍ដែលអាចជាហាងលក់ដូរឥវ៉ាន់ អាហារដ្ឋាន ឬការថែរក្សាសុខភាព។ល។ សម្រាប់សម្រួលដល់ជីវភាពរស់នៅរបស់សមាជិកខ្លួន
- ចំណាយលើតួនាទីផ្នែករដ្ឋបាលនៅក្នុងការផ្តល់ឱ្យនូវអត្ថប្រយោជន៍ដល់សមាជិករបស់ខ្លួន ពេលគ្មានការងារធ្វើ
- .......................................................

សមាជិកមានសិទ្ធិស្នើសុំការពន្យល់បង្ហាញ ពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សហព័ន្ធសហជីព។

**ប្រការ១៩ ._** *(ការចាត់ចែងទ្រព្យសម្បត្តិ នៅពេលរំលាយ ឬរលាយ)*

ក្នុងករណីដែលសហព័ន្ធសហជីព/សហភាពសហជីពត្រូវបានរំលាយ ឬរលាយស្របទៅតាមលក្ខន្តិកៈ ឬបទប្បញ្ញត្តិជាធរមាន ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សហព័ន្ធសហជីព/សហភាពសហជីព ត្រូវបែងចែកដូចខាងក្រោម៖

- ធ្វើជាអំណោយទៅឱ្យសហជីពដែលមានសកម្មភាពដូចគ្នា ឬប្រហាក់ប្រហែល
- ..............................................................

## ជំពូកទី៧
## ការថែរក្សាកំណត់ត្រាហិរញ្ញវត្ថុ
## របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាពប្រចាំឆ្នាំ

**ប្រការ២០ ._** *(ការថែរក្សាកំណត់ត្រាហិរញ្ញវត្ថុ)*

អគ្គហេរញ្ញិកមានករណីយកិច្ចរក្សាទុកនូវវិក្កយបត្រ សក្ខីបត្រ របាយការណ៍ធនាគារ ដើម្បីកត់ត្រាចូលកំណត់ត្រាហិរញ្ញវត្ថុប្រចាំថ្ងៃ និងធ្វើសៀវភៅហិរញ្ញវត្ថុប្រចាំខែ ឆ្នាំ ស្របទៅតាមទម្រង់បែបបទដែលកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

សៀវភៅហិរញ្ញវត្ថុ និងកំណត់ត្រាហិរញ្ញវត្ថុត្រូវរក្សាទុកនៅទីស្នាក់ការរបស់សហព័ន្ធសហជីព/សហភាពសហជីព.......................... ដែលមានអាសយដ្ឋានផ្ទះលេខ....... ផ្លូវ........... ភូមិ.......... ឃុំ/សង្កាត់............... ស្រុក/ខណ្ឌ/ក្រុង........... រាជធានី/ខេត្ត........................។

**ប្រការ២១ ._** *(របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាពប្រចាំឆ្នាំ)*

អគ្គលេខាធិការ និងអគ្គហេរញ្ញិក ត្រូវសហការគ្នាធ្វើរបាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយផ្អែកលើកំណត់ត្រាហិរញ្ញវត្ថុប្រចាំថ្ងៃ និងសៀវភៅហិរញ្ញវត្ថុប្រចាំខែ ដើម្បីបង្ហាញជូនដល់សមាជិករបស់ខ្លួនជ្រាប និងចម្លងជូនអង្គភាពទទួលបន្ទុកចុះបញ្ជីចំនួន១(មួយ)ច្បាប់ យ៉ាងយូរត្រឹមដំណាច់ខែមីនានៃឆ្នាំបន្ទាប់។

សហជីពត្រូវបោះពុម្ពផ្សាយជាប្រចាំនូវរបាយការណ៍ប្រចាំឆ្នាំអំពីស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន។

..............................................................................

## ជំពូកទី៨
## សន្និបាត

**ប្រការ២២ ._** *(សន្និបាត)*

មហាសន្និបាតគឺជាអង្គការចាត់តាំងខ្ពស់បំផុតរបស់សហព័ន្ធសហជីព/សហភាពសហជីព ដែលធ្វើឡើងជារៀងរាល់..........ឆ្នាំម្តង។ សន្និបាតប្រចាំឆ្នាំត្រូវធ្វើឡើងជារៀងរាល់១(មួយ)ឆ្នាំម្តង។

ប្រធានមហាសន្និបាត ឬសន្និបាតរាយការណ៍ជូនអង្គមហាសន្និបាត ឬសន្និបាត នូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាពប្រចាំឆ្នាំ ឬប្រចាំអាណត្តិរបស់ខ្លួន ដើម្បីឱ្យសមាជិកមហាសន្និបាត ឬសន្និបាតពិនិត្យអនុម័ត។

សមាជិកមានសិទ្ធិបញ្ចេញមតិយោបល់ លើកសំណូមពរ និងសំណួរជូនអង្គមហាសន្និបាត ឬសន្និបាត ដើម្បីពិនិត្យពិភាក្សា និងអនុម័ត។

កូរ៉ុមសម្រាប់ដំណើរការមហាសន្និបាត ត្រូវស្មើនឹង៥០%+១ (ហាសិបភាគរយបូកមួយ) នៃចំនួនកម្មករនិយោជិតសរុប ដែលជាសមាជិកសហព័ន្ធសហជីព/សហភាពសហជីព។ រាល់សេចក្តីសម្រេចនៅក្នុងមហាសន្និបាតត្រូវអនុម័តដោយសំឡេង......... *(ចំនួនយ៉ាងតិច៥០%+១)* នៃសមាជិកដែលចូលរួមមហាសន្និបាត។

ក្នុងករណីចាំបាច់ មហាសន្និបាតវិសាមញ្ញ ឬសន្និបាតវិសាមញ្ញអាចធ្វើទៅបានតាមការស្នើសុំរបស់សមាជិកចំនួន........ *(យ៉ាងតិច២០%)* នៃចំនួនសមាជិកសរុប។

## ជំពូកទី៩
## ការរៀបចំបទបញ្ជាផ្ទៃក្នុង ការកែប្រែលក្ខន្តិកៈ និងការរំលាយ

**ប្រការ២៣ ._** *(បទបញ្ជាផ្ទៃក្នុង)*

បទបញ្ជាផ្ទៃក្នុងរបស់សហព័ន្ធសហជីព/សហភាពសហជីព........................................ ត្រូវអនុម័តដោយមហាសន្និបាត ឬសន្និបាត។

**ប្រការ២៤ ..** *(ការកែប្រែលក្ខន្តិកៈ)*

ការកែប្រែលក្ខន្តិកៈសហព័ន្ធសហជីព/សហភាពសហជីពអាចធ្វើទៅបាន លុះត្រាតែមានសំណើរបស់កម្មករ និយោជិតដែលជាសមាជិកសហព័ន្ធសហជីព/សហភាពសហជីពចំនួន.... *(ចំនួនយ៉ាងតិច២០%)* នៃចំនួនកម្មករ និយោជិតដែលជាសមាជិកសរុបរបស់សហព័ន្ធសហជីព/សហភាពសហជីព ហើយត្រូវបានអនុម័តដោយមហាសន្និបាត។

**ប្រការ២៥ ..** *(ការរំលាយ)*

សហព័ន្ធសហជីព/សហភាពសហជីពអាចត្រូវបានរំលាយតាមវិធីណាមួយ ដូចខាងក្រោម៖

- សហព័ន្ធសហជីព/សហភាពសហជីពត្រូវបានរំលាយ តាមរយៈការបោះឆ្នោតសម្រេចដោយសំឡេង...... *(យ៉ាងតិច៥០%+១)* របស់កម្មករ និយោជិត ដែលជាសមាជិករបស់សហព័ន្ធសហជីព/សហភាពសហជីព នៅក្នុងមហាសន្និបាត បន្ទាប់ពីមានសំណើសុំរំលាយពីកម្មករ និយោជិតដែលជាសមាជិកសហព័ន្ធសហជីព/សហភាពសហជីព ចំនួនយ៉ាងតិច៥០%(ហាសិបភាគរយ)
- សហព័ន្ធសហជីព/សហភាពសហជីពត្រូវរំលាយដោយស្វ័យប្រវត្តិ ក្នុងករណីដែលសហព័ន្ធសហជីព/សហភាពសហជីពលែងមានសមាជិកគ្រប់ចំនួនអប្បបរមាដែលតម្រូវដោយច្បាប់
- ..............................................................................................។

## ជំពូកទី១០
## កូដកម្ម

**ប្រការ២៦ ..** *(សិទ្ធិធ្វើកូដកម្ម)*

សិទ្ធិធ្វើកូដកម្មនៃសមាជិកសហព័ន្ធសហជីព/សហភាពសហជីព គឺជាសិទ្ធិរបស់សហជីពមូលដ្ឋាន ដែលជាសមាជិកនៃសហព័ន្ធសហជីព/សហភាពសហជីព ក្រោយពេលមានការសម្រេចយល់ព្រមឱ្យធ្វើកូដកម្មរបស់កម្មករ និយោជិតដែលជាសមាជិកសហជីពមូលដ្ឋាននីមួយៗស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

សហព័ន្ធសហជីព/សហភាពសហជីពអាចផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ពាក់ព័ន្ធនឹងការធ្វើកូដកម្មរបស់សហជីពមូលដ្ឋានដែលជាសមាជិករបស់ខ្លួន។

....................

**ប្រការ២៧ ..** *(ការបោះឆ្នោតសម្រេចធ្វើកូដកម្ម)*

សំណើធ្វើកូដកម្មត្រូវសម្រេចតាមរយៈការបោះឆ្នោតជាសម្ងាត់ដោយផ្ទាល់ពីកម្មករ និយោជិតដែលជាសមាជិកសហជីព ដោយក្វ៉ុមប្រជុំចំនួនភាគច្រើនដាច់ខាត (យ៉ាងតិច ៥០%+១) នៃសមាជិកសហព័ន្ធសហជីព/សហភាពសហជីពសរុប។ ការសម្រេចធ្វើកូដកម្មត្រូវអនុម័តដោយសំឡេងយ៉ាងតិច ៥០%+១ (ហាសិបភាគរយបូកមួយ) នៃចំនួនសមាជិកដែលចូលរួមកិច្ចប្រជុំសម្រេចធ្វើកូដកម្ម។

កម្មវត្ថុនៃការធ្វើកូដកម្ម ត្រូវស្របតាមគោលបំណង គោលដៅ និងដែនអនុវត្តរបស់សហជីព និងត្រូវអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

នីតិវិធីក្នុងការធ្វើកូដកម្មត្រូវអនុវត្តស្របតាមច្បាប់ស្តីពីការងារ និងបទប្បញ្ញត្តិជាធរមាន សំដៅរក្សាផលប្រយោជន៍របស់កម្មករ និយោជិត និងសណ្តាប់ធ្នាប់សាធារណៈ។

## ជំពូកទី១១
## អ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាល

**ប្រការ២៨ ..** *(លក្ខខណ្ឌសម្រាប់អ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាល )*

អ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សហព័ន្ធសហជីព/សហភាពសហជីព ដែលជាពលរដ្ឋខ្មែរ ត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

- មានអាយុយ៉ាងតិច១៨(ដប់ប្រាំបី)ឆ្នាំ
- មានកម្រិតវប្បធម៌យ៉ាងហោចណាស់ចេះអាន ចេះសរសេរអក្សរខ្មែរ

- មិនធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ
- មានអតីតភាពក្នុងសហគ្រាស គ្រឹះស្ថានយ៉ាងតិច.......
- ............................................................។

អ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សហព័ន្ធសហជីព/សហភាពសហជីព ដែលជាជនបរទេស ត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

- មានអាយុយ៉ាងតិច១៨(ដប់ប្រាំបី)ឆ្នាំ
- ចេះអាន និងចេះសរសេរអក្សរខ្មែរ
- បាននិងកំពុងធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាយ៉ាងតិច ២(ពីរ)ឆ្នាំ
- មិនធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ
- មានអតីតភាពក្នុងសហគ្រាស គ្រឹះស្ថានយ៉ាងតិច.......
- មានសិទ្ធិស្នាក់នៅ និងមានទីលំនៅអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រឹមត្រូវតាមច្បាប់ស្តីពីអន្តោប្រវេសន៍នៃព្រះរាជាណាចក្រកម្ពុជា
- ..................................................។

**ប្រការ២៩ ៖** *(ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំ)*

ការបោះឆ្នោតជ្រើសរើសអ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សហព័ន្ធសហជីព/សហភាពសហជីព ត្រូវធ្វើឡើងក្នុងមហាសន្និបាត តាមរយៈការបោះឆ្នោតជាសម្ងាត់។

អាណត្តិសម្រាប់មុខតំណែងអ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលមានរយៈពេល.......ឆ្នាំ។ អ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលអាចឈរឈ្មោះបោះឆ្នោតជាថ្មីឡើងវិញបាន។

...................................................................។

## ជំពូកទី១២
## អន្តរប្បញ្ញត្តិ

**ប្រការ៣០ ៖**

.....................................................................................

## ជំពូកទី១៣
## អវសានប្បញ្ញត្តិ

**ប្រការ៣១ ៖** *(សុពលភាពអនុវត្ត)*

លក្ខន្តិកៈសហព័ន្ធសហជីព/សហភាពសហជីព...................................... ត្រូវបានមហាសន្និបាតអនុម័ត នៅថ្ងៃទី..... ខែ....... ឆ្នាំ......... ដោយសំឡេង...... និងមានសុពលភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើជា... *(យ៉ាងតិច៣)* ច្បាប់ដើម នៅ........... ថ្ងៃទី... ខែ....... ឆ្នាំ..........

**ប្រធាន**